ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៦៨៩ / ១៨-០៧-២០១២

**សាលដីកា**

លេខ ០១ "ក្រ.III.ច" / ១១-០២-២០១៤

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ ភ្នំពេញ**

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើ តាមក្រិត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ២២-០១-២០១៤ ដោយមានសមាសភាពដូចតទៅៈ

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

**លោកស្រី** [redacted] **ជាប្រធានក្រុមប្រឹក្សា**

**លោក** [redacted] **ជាចៅក្រមប្រឹក្សា**

**លោក** [redacted] **ជាចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**ឯកឧត្តម** [redacted] **ជាអគ្គព្រះរាជអាជ្ញារង**

**ក្រឡាបញ្ជី**

**លោក** [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៦៨៩ ចុះថ្ងៃទី ១៨-០៧-២០១២ ដោយមានៈ

**១-ជនជាប់ចោទឈ្មោះ** [redacted] មូ ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរយោធិន ទីកន្លែងកំណើតនៅភូមិឫស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅ[redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ទោសពីមុនគ្មាន ពន្ធនាគារខេត្តស្វាយរៀង ។

-មានមេធាវីការពារសិទ្ធិលោក[redacted]សំអាត ។



ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

Scanned with CamScanner

-ជាប់ចោទពីបទ: សមគំនិតក្នុងអំពើប្លន់ប្រដាប់អាវុធ ប្រព្រឹត្តនៅព្រំប្រទល់កម្ពុជា-វៀតណាម រវាងភូមិត្រស់ ឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង និងភូមិវ៉ាប៊ិន ឃុំវ៉ាហ៊ីប ស្រុកគិរីវង់ ខេត្តតាកែវ... ខេត្តតែនិញ កាលពីថ្ងៃទី០៩-មករា-២០០៧ បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាម បញ្ញត្តិមាត្រា ៦៩នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**៦រឿងហេតុមានដូចតទៅៈ**

កាលពីយប់ថ្ងៃទី ០៩-មករា-២០០៧ មានចោរមួយក្រុមមានគ្នា ០៧នាក់ប្រដាប់អាវុធ អាកាចំនួន ០២ដើម បានធ្វើសកម្មភាពចូលប្លន់ទ្រព្យសម្បត្តិរបស់ប្រជាជនវៀតណាម នៅត្រង់ចំណុចព្រំប្រទល់កម្ពុជា-វៀតណាម រវាងភូមិវ៉ាប៊ិន ឃុំវ៉ាហ៊ីប ស្រុកតឹងបៀន ខេត្តតៃនិញ និងភូមិត្រស់ ឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង ដោយប្លន់យកបានប្រមាណ ៥០តំលឹង ប្លាទីន ១០០ តំលឹង និងប្រាក់ដុង ៨.០០០.០០០ ដុង ព្រមទាំងបាញ់រះបណ្ដាលឲ្យប្រជាជនវៀតណាមរងរបួស ០៣នាក់ រួចហើយក្រុមចោរបាននាំគ្នារត់គេចខ្លួនចូលក្នុងភូមិត្រស់ ឃុំត្រស់ ក្នុងទឹកដីកម្ពុជា តែនៅពេលរត់គេចខ្លួនក្រុមចោរបានបន្សល់ទុកចោលនូវក្រមា និងមួកមួយផងនៅព្រំដែនកម្ពុជា វៀតណាម ។

-**បានឃើញ**សាលាដំបូងខេត្តស្វាយរៀង បានសម្រេចសាលក្រមព្រហ្មទណ្ឌលេខ ២៩ "គ" ចុះថ្ងៃទី ០៥.០៦.២០០៧ បានសម្រេចសេចក្ដីថា៖

១-ផ្តន្ទាទោសចំពោះមុខឈ្មោះ [redacted] ហ៊ាប , [redacted] ខុន , [redacted] សារិត និង [redacted] ម៉ិ ដាក់ពន្ធនាគារម្នាក់ៗ កំណត់ ០៩ (ប្រាំបួន) ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនម្នាក់ៗតមក និងផ្តន្ទាទោសកំបាំង មុខឈ្មោះ [redacted] វណ្ណា , [redacted] មាឌ , [redacted] សារុត ដាក់ពន្ធនាគារម្នាក់ៗកំណត់ ០៩ (ប្រាំបួន) ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន (ទាំង ០៧នាក់) ពីបទ រួបរួមគ្នាប្លន់ប្រដាប់អាវុធ ប្រព្រឹត្តនៅព្រំប្រទល់កម្ពុជា វៀតណាម រវាង ភូមិត្រស់ ឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង និងភូមិវ៉ាប៊ិន ឃុំវ៉ាហ៊ីប ស្រុកតឹងបៀន ខេត្ត តៃនិញ កាលពីថ្ងៃទី ០៩.០១.២០០៧ តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

២-ផ្តន្ទាទោសកំបាំងមុខឈ្មោះ [redacted] បូ និងឈ្មោះ [redacted] ឈាន ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១០ (ដប់) ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន (ទាំងពីរនាក់) ពីបទ សមគំនិតក្នុងបទប្លន់ប្រដាប់អាវុធ ប្រព្រឹត្តនៅទីកន្លែង និងពេលវេលាដូចក្នុងប្រការ ១ ខាងលើ តាមបញ្ញត្តិមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-វត្ថុតាងគឺមាស ចំនួន ០៥ (ប្រាំ) ជី ០៣ (បី) ហ៊ុន ០៥ (ប្រាំ) លី , ប្លាទីនចំនួន ០១ (មួយ) តំលឹង ០៣ (បី) ជី ០៣(បី) ហ៊ុន , ប្រាក់រៀល ២០.០០០ (ពីរម៉ឺន) រៀល ប្រាក់ដុល្លា ០២ (ពីរ) ដុល្លា ត្រូវរឹបអូសរួចប្រគល់ឲ្យទៅជនរងគ្រោះឈ្មោះ [redacted] ធីថើម វិញ ។ ស៊ីមកាត ០៩២ ៥៥ ៦៥ ៨៥ និងទូរស័ព្ទដៃ ០៩២ ៧២ ៨៩ ៦១ ត្រូវរឹបអូសរក្សាទុក ។ ឯអត្តសញ្ញាណប័ណ្ណឈ្មោះ [redacted] សុភី ត្រូវ



Scanned with CamScanner

វិប្បូសរុបប្រគល់ឲ្យឈ្មោះនេះវិញ ។

៤-បើកផ្លូវឲ្យឈ្មោះ [redacted] ធីថើម (ជនរងគ្រោះ) ប្ដឹងទៅតុលាការរដ្ឋប្បវេណីក្នុងកំណត់ច្បាប់ដើម្បីទារសំណងបន្ថែមពីការអន្តរាយបណ្ដាលមកពីអំពើរបស់ជនល្មើសទាំង ០៩ នាក់ក្នុងប្រការ១ និងប្រការ២ នៃសេចក្ដីសំរេចនេះ ។

៥-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខឈ្មោះ [redacted] ហ៊ាប , ទន់ ខុន , [redacted] សារិត និងឈ្មោះ [redacted] ម៉ិ កំបាំងមុខឈ្មោះ [redacted] វណ្ណា , [redacted] មាឌ , [redacted] សាវុត , [redacted] បូ និង [redacted] ឈាន ។ បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមបញ្ញត្តិច្បាប់ ។

**-បានឃើញ**សាលាដំបូងខេត្តស្វាយរៀង បានសម្រេចសាលក្រមព្រហ្មទណ្ឌលេខ ៤៣ "ខ" ចុះថ្ងៃទី ០៧.០៩.២០១០ បានសម្រេចសេចក្ដីថា ៖

១-ទទួលពាក្យបណ្ដឹងទាស់របស់ឈ្មោះ [redacted] បូ ចុះថ្ងៃទី ២៧.០៥.២០១០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលទាំងស្រុងដោយខុស និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ ២៩ (គ) ចុះថ្ងៃទី ០៥.០៦.២០០៧ របស់តុលាការខេត្តស្វាយរៀង ទុកជាបានការពេញទាំងមូល ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] បូ ។ ទុកសិទ្ធិអោយប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍លេខជនជាប់ចោទឈ្មោះ [redacted] **បូ** ប្ដឹងនិងសាលក្រមព្រហ្មទណ្ឌលេខ ៤៣ "ខ" ចុះថ្ងៃទី ០៧-០៩-២០១០ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុច នៃសេចក្ដីសម្រេច ។

**បានឃើញ**របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

**បានឃើញ**សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

-ជនជាប់ចោទឈ្មោះ [redacted] **បូ** ថា ខ្លួនទទួលកំហុសដែលបានចូលរួមគំនិតប្រព្រឹត្តបទល្មើស ខ្លួនជាអ្នកប្រាប់ឈ្មោះ ប៉ែត បានឱ្យយកកាំភ្លើងទៅឱ្យពួកខ្លួនឈ្មោះ [redacted] មាឌ ក្រុម [redacted] មាឌ បានទៅប្លន់អ្នកលក់មាស ពេលប្លន់បានមាស និងប្លាទីននោះ ខ្លួនមិនទាន់បានចំណែកទេ ។ មូលហេតុបែកគំនិតប្លន់នោះដោយសាររកស៊ីលក់ក្របី ត្រូវគេបោក ដឹងកំហុសហើយ សុំកែខ្លួន សុំបន្ធូបន្ថយទោស ។

**តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន**

ជនជាប់ចោទបានសារភាពនូវកំហុសហើយ សុំបន្ធូបន្ថយទោស ជនជាប់ចោទត្រូវបានដាក់./.



Scanned with CamScanner

ទណ្ឌកម្ម១០ឆ្នាំ ទណ្ឌកម្មនៅទាប សុំតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការ ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន**

កូនក្តីខ្លួនបានសារភាពនូវកំហុសអស់ហើយ មិត្តភក្រ្តិជាអ្នកអូសទាញ បានជាប់ទោសអស់រយៈពេលជាយូរមកហើយ ត្រូវបានសាលាដំបូងចោទប្រកាន់តាមមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សុំកែប្រែមកតាមមាត្រា ៣៥៧ , ២៩ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ វិញ និងសុំបន្ធូបន្ថយទោស ។

**តុលាការថយទៅពិភាក្សា**

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។

ក្រោយពីបានស្តាប់ជនជាប់ចោទឆ្លើយ និងសំណូមពរ។

ក្រោយពីបានស្តាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន។

ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសន្និដ្ឋាន។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

**សាលាឧទ្ធរណ៍**

**យល់ឃើញថាៈ**

១-បណ្តឹងឧទ្ធរណ៍លេខ ៣៩ ចុះថ្ងៃទី ០១.១០.២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ម្ចូ ប្តឹងនិងសាលក្រមព្រហ្មទណ្ឌលេខ ៨៣ "ខ" ចុះថ្ងៃទី ០៧-០៩-២០១០ របស់សាលាដំបូងខេត្តស្វាយរៀង ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ចម្លើយរបស់ជនជាប់ចោទនៅប៉ូលីស (ឯ ១៩១/២) និងនៅពេលសវនាការនៅសាលាឧទ្ធរណ៍ ជនជាប់ចោទបានទទួលសារភាពថាខ្លួនពិតជាបានចូលរួមផ្តល់គំនិតនិងផ្តល់សំភារៈដែលឲ្យ កាំភ្លើងទៅពួកខ្លួនប្រព្រឹត្តបទល្មើសមែន ។

៣-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់ ទៅលើជនជាប់ចោទឈ្មោះ [redacted] ម្ចូ ពីបទៈ សមគំនិតប្លន់ ប្រព្រឹត្តនៅព្រំប្រទល់កម្ពុជា វៀតណាម រវាង ភូមិត្រស់ ឃុំត្រស់ ស្រុកមោសហែក ខេត្តស្វាយរៀង និងភូមិវ៉ាប៊ិន ឃុំវ៉ាហ៊ីប ស្រុកតឹងបៀន ខេត្តតៃនិញ កាលពពីថ្ងៃទី ០៩.០១.២០០៧ តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៣ (ខ) ចុះថ្ងៃទី ០៧.០៩.២០១០ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការ គ្រាន់តែសាលាឧទ្ធរណ៍កែប្រែមាត្រាបទចោទតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌលើជនជាប់ចោទឱ្យត្រឹមត្រូវតាមច្បាប់ ដែលសាលាដំបូងសម្រេចចោទប្រកាន់តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌ



Scanned with CamScanner

អន្តរកាល មកតាមមាត្រា ១០ , ៣៥៧ , ២៩ នៃក្រមព្រហ្មទណ្ឌវិញ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៩ ចុះថ្ងៃទី ០១.១០.២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ម្ញូ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៣ "ខ" ចុះថ្ងៃទី ០៧.០៩.២០១០ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការលើកលែងតែចំណុចទី២ ដែលតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៩ "គ" ចុះថ្ងៃទី ០៥.០៦.២០០៧ ត្រូវកែប្រែ:

ក-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ម្ញូ ពីបទ:សមគំនិតក្នុងអំពើប្លន់តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មកមាត្រា ១០ , ៣៥៧ , ២៩ នៃក្រមព្រហ្មទណ្ឌ ។

ខ-ផ្តន្ទាទោសឈ្មោះ [redacted] ម្ញូ ភេទប្រុស ដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួនពីបទ: សមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តនៅព្រំប្រទល់កម្ពុជា វៀតណាម រវាងភូមិត្រស់ ឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង និងភូមិវ៉ាំបិន ឃុំវ៉ាំហ៊ីប ស្រុកតឹងបៀន ខេត្តតៃនិញ កាលពីថ្ងៃទី ០៩.០១.២០០៧ តាមបញ្ញត្តិមាត្រា ១០ , ៣៥៧ , ២៩ នៃក្រមព្រហ្មទណ្ឌ ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីការនេះជំនុំជំរះជាសាធារណៈថ្ងៃទី ២២.០១.២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១១.០២.២០១៤ កំបាំងមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី ១១ ខែ ៤ ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]



១៩៧

Scanned with CamScanner